**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ :........០១១..../២៣..................ក.ប/ស.ជ.ក**

# សេចក្តីជូនដំណឹង

# ស្តីពី

# ការប្រារព្ធខួបអនុស្សាវរីយ៍លើកទី១៣៧ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងអំពីការរៀបចំ ប្រារព្ធខួបអនុស្សាវរីយ៍លើកទី១៣៧ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣ ដូចតទៅ៖

១-ការរៀបចំប្រារព្ធខួបអនុស្សាវរីយ៍លើកទី១៣៧ នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា ក្រោមប្រធានបទ "**សន្តិភាព ស្ថិរភាព មុខរបរ និងការងារ**"។

២-គ្រប់ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំចាត់តាំងពិធីជួបជុំសំណេះសំណាល អបអរសាទរទិវាពលកម្មអន្តរជាតិ ១ ឧសភា នៅតាមមូលដ្ឋានរៀងៗខ្លួន និងសហការជាមួយសហគ្រាស គ្រឹះស្ថានអង្គការសហជីព ដើម្បីផ្សព្វផ្សាយសារាចរណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា សារលិខិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

៣-ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលរាជធានី ខេត្តទាំងអស់ និងរោងចក្រ សហគ្រាស គ្រឹះស្ថាន ត្រូវជ្រើសរើសទីតាំងសមស្រប ដូចជា ផងវិថីសំខាន់ៗ និងទីតាំងរោងចក្រ សហគ្រាស ការដ្ឋាន និងកសិដ្ឋាន ដើម្បីធ្វើការចងបដាពាក្យស្លោកតាមខ្លឹមសារដូចខាងក្រោម៖

- ជយោ! ព្រះរាជាណាចក្រកម្ពុជា
- អបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣៧ នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា
- សន្តិភាព ស្ថិរភាព មុខរបរ និងការងារ
- គោរពច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីសហជីព ដើម្បីធានាសិទ្ធិ និងផលប្រយោជន៍រួមរបស់កម្មករនិយោជិត និងនិយោជក
- អនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម ដើម្បីសុខុមាលភាពកម្មករនិយោជិត និងប្រជាពលរដ្ឋ
- អភិវឌ្ឍជំនាញវិជ្ជាជីវៈ ដើម្បីបង្កើនផលិតភាព និងភាពប្រកួតប្រជែង
- ប្តេជ្ញាបន្តអនុវត្តអនុសាសន៍គន្លឹះ ១០ចំណុច របស់សម្តេចតេជោនាយករដ្ឋមន្ត្រី
- ចូលរួមអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន ដើម្បីអនាគត។

៤-គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត ត្រូវតាមដាន និងបូកសរុបរបាយការណ៍លទ្ធផលនៃការរៀបចំពិធីនេះ ជូនរដ្ឋបាលរាជធានី ខេត្ត និងក្រសួង។ ៗ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានក្តីសង្ឃឹមយ៉ាងមុតមាំថា ក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត សមាគមនិយោជក និយោជក អង្គការសហជីព និង កម្មករនិយោជិតនៃរោងចក្រ សហគ្រាស គ្រឹះស្ថានទាំងអស់ នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយ ប្រសិទ្ធភាពខ្ពស់។

ថ្ងៃ សុក្រ ២កើត ខែ ពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ២០២៣

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
-គ្រប់សាលារាជធានី ខេត្ត
-គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត
-គ្រប់សមាគមនិយោជក
-គ្រប់អង្គការសហជីព
-ឯកសារ-កាលប្បវត្តិ